


Les berges du lac Kankaria à Ahmedabad (Inde) permettent une promenade continue et des espaces de repos végétalisés et ombragés
មាត់បឹងកាន់ការៀ( Kankaria ) នៅទីក្រុងអាម៉េដាបាត(Ahmedabad)( ប្រទេសឥណ្ឌា )ដែលអនុញ្ញាតឱ្យមានការដើរកម្សាន្តជាប្រចាំ
និងទីកន្លែងសម្រាកដែលមានដាំរុក្ខជាតិនិងមានម្លប់រុក្ខជាតិ។




Le lac Kankaria, vue à vol d'oiseau, un écrin de fraîcheur au milieu des tumultes de la ville indienne d'Ahmedabad au climat semi-aride
បឹងកាន់ការៀ( Kankaria )មើលពីលើអាកាស លំហខ្យល់ត្រជាក់នៅកណ្តាលភាពអ៊ូអរ នៅទីក្រុងប្រទេសឥណ្ឌាអាម៉េដាបាត( Ahmedabad ) ដែលមាន
អាកាសធាតុពាក់កណ្តាលស្ងួតហួតហែង។

ក្លាយជាកន្លែងដែលគេស្គាល់ច្រើន ដោយសារមានកន្លែងប្រវត្តិសាស្ត្រមួយកន្លែង ដែលរំឭកពីការសម្លាប់រង្គាលក្នុងសម័យខ្មែរក្រហម មានស្ថានីយ បុរាណវិទ្យាសំខាន់មួយ ដែលមានរាងជារង្វង់បង្កើតឡើងដោយទំនប់តៗគ្នាមួយខ្សែ។ ស្ថានីយបុរាណវិទ្យានេះមានអាយុកាលតាំងពីសតវត្សរ៍ទី ៧ ហើយការស្រាវជ្រាវអំពីប្រវត្តិនិងការដើរតួនាទីរបស់វាកំពុងដំណើរការ។
ទីតាំងរមណីយដ្ឋានមួយនេះ ត្រូវបានក្រសួងវប្បធម៌កម្ពុជាថែរក្សាការពារ ។
ដូច្នេះ ភាគខាងត្បូងក្រុងភ្នំពេញ គឺជាកន្លែងវប្បធម៌សម្បូណ៌បែបនិងមានទេសភាពទឹកបឹងដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន។

**ទីក្រុង និងបឹងកំពុងផ្លាស់ប្តូរមុខមាត់ថ្មី**
ចាប់តាំងពីប៉ុន្មានឆ្នាំមកនេះបើគេមើលពីចម្ងាយ គេឃើញសុទ្ធតែអគារខ្ពស់ៗដុះនៅកណ្តាលក្រុងភ្នំពេញ។
ទីក្រុងកាន់តែខិតចូលជិតគ្នា ហើយនិង សកម្មជាងមុន។ បឹងនេះផ្ទាល់ក៏មានការផ្លាស់ប្តូរមុខមាត់ថ្មីដែរ។ មហាវិថី សម្តេច ហ៊ុន សែន ដែលសង់នៅលើបឹង កំពុងលុបទេសភាពដ៏ស្ងប់សុខរបស់ទីជនបទដែលសម្បូរដោយទឹក និងការដាំដុះបន្លែនៅមាត់ទ្វារក្រុង។
អំណើះតទៅ បឹងជើងឯក នឹងមានលក្ខណៈជាក្រុង ហើយគេធ្វើយ៉ាងណាឲ្យទទួលបានជោគជ័យក្នុងការផ្លាស់ប្តូរ ពីទេសភាពជនបទទៅជាទេសភាពក្រុង។ បឹងជើងឯក មានគុណសម្បត្តិជាច្រើនសម្រាប់ក្រុងភ្នំពេញ។ វត្តមាននៃបឹងដ៏ធំដែលព័ទ្ធជុំវិញដោយក្រុងដែលត្រូវបានរៀបចំគឺជាធាតុនៃការលើកតម្លៃដ៏សំខាន់មួយ។
ទេសភាពបឹងនឹងក្លាយជាចំណុចកណ្តាល និងផ្តល់អត្តសញ្ញាណឲ្យទីក្រុងថ្មី។
ទីក្រុងធំៗរបស់ប្រទេសដទៃបានប្រើប្រាស់បឹងធម្មជាតិរបស់ខ្លួនដើម្បីធ្វើជាឧទ្យានក្រុង។ ក្រុងហាណូយ គឺជាឧទាហរណ៍ដ៏ល្អមួយដោយហេតុថា ក្រុងនេះបានអភិវឌ្ឍនៅក្នុងបណ្តាញព្រែកជីក បឹងនិងទំនប់ ។ ការពង្រីកក្រុងហាណូយបាន ប៉ះពាល់ដល់ដីស្រែនិងភូមិតូចៗ ដែលពីដើមធ្លាប់ជាទីជនបទនៃតំបន់ទន្លេក្រហម។
ក៏ប៉ុន្តែ នៅកណ្តាលទីរួមក្រុង បឹងហ័នកៀម «ដួងព្រលឹងរដ្ឋធានី» ត្រូវបានអភិរក្ស និងព័ទ្ធជុំវិញដោយកន្លែងដើរកំសាន្ត និងសួនច្បារ។
បឹងនេះបានក្លាយជាកន្លែងនិមិត្តរូបសំខាន់មួយរបស់សង្កាត់ប្រវត្តិសាស្ត្រ។ បឹងបានធ្វើឲ្យរបស់ដែលនៅជុំវិញវាមានតម្លៃ។ មានមនុស្សចេញចូលច្រើននៅទីរមណីយដ្ឋានមួយនេះ។ អគារពាណិជ្ជកម្មជាច្រើនបានបោះទីតាំងនៅទីនោះ ហើយកម្មវិធីផ្សេងៗ ដូចជាការប្រគំតន្ត្រី និងសកម្មភាពកីឡាក៏ប្រព្រឹត្តឡើង នៅទីនោះដែរ។
បរិយាកាសដូចគ្នានេះក៏មាននៅតាមច្រាំងបឹង ហូបាយម៉ៅដែលស្ថិតនៅខាងត្បូងក្រុង គឺស្ថិតនៅក្នុងឧទ្យាន ថោងឬនៅតាមច្រាំងអតីតដៃទន្លេក្រហម គឺបឹងខាងលិច ឈ្មោះថា ហូតៃដែលសព្វថ្ងៃក្លាយជាបឹងធំជាងគេ នៅក្រុងហាណូយ ដែលមានទំហំ ៥០០ ហិចតា។ ដូចនៅ ទីក្រុង វ៉ង់ហ្គូនដែរ ទីប្រជុំក្រុងត្រូវបានការពារពីទឹកជំនន់ដោយបឹងធំមួយ ដែលទទួលទឹកភ្លៀងហូរចាក់មកពីមួយផ្នែកធំនៃទីក្រុង ដែលហ៊ុមដោយឧទ្យាន។
ទីក្រុងអាម៉េដាប៉ាដវិញ Ahmedabad មាននៅជាប់បឹង Kankaria សម្បូរដោយសកម្មភាពវប្បធម៌ និងការកំសាន្តនានា។

**ការបង្កើតឧទ្យានសាធារណៈធំមួយដែលមានបឹងនៅកណ្តាល**
បឹងជើងឯក មានទំហំធំល្អដើម្បីក្លាយជាឧទ្យានសាធារណៈធំជាងគេនៃទីក្រុងភ្នំពេញ។ ចំពោះបញ្ហានេះ សំណង់ទាំងឡាយគឺមិនត្រូវសង់បែរខ្នងដាក់បឹងនោះទេ ប៉ុន្តែ បឹងត្រូវក្លាយជាកន្លែងស្នូលដូចជាឧទ្យាន Central Park នៅក្រុងញូវយ៉កដែរ។
លក្ខណៈសម្បត្តិរបស់កន្លែងនេះ ដែលជាបឹងធំមួយមានដាំដើមឈើតាមច្រាំង និងហ៊ុំព័ទ្ធដោយកន្លែងដើរលេង និងមហាវិថីធំមួយ នឹងធ្វើឲ្យវាក្លាយជាចលករមួយនៃនគរូបនីយកម្ម និងកន្លែងស្រស់ស្អាតគួរជាទីគយគន់។ វានឹងធ្វើឲ្យមានអធិកលាភដីធ្លី ( ការឡើងថ្លៃដីធ្លី ) ជាប្រយោជន៍ដល់ទាំងអស់គ្នា ដល់សាលារាជធានីដែលនឹងសម្រេចបាននូវឧទ្យានមួយ និងដល់ប្រជាជនភ្នំពេញដែលនឹងប្រើប្រាស់វាហើយនិងដល់វិនិយោគិនដែលយកវាសម្រាប់ផ្សព្វផ្សាយពាណិជ្ជកម្ម។
ក្នុងពេលដែលមានការប្រែប្រួលអាកាសធាតុ ស្រមៃមើលសួនឧទ្យានដ៏ធំមួយ ព័ទ្ធជុំវិញបឹង ដ៏ធំអស្ចារ្យ គឺបានផ្តល់ទៅប្រកបដោយគុណភាពខ្យល់បរិសុទ្ធនៅកណ្តាលក្រុង និងបឹងធំមួយសម្រាប់មនុស្សជំនាន់ក្រោយ។
ដូច្នេះ បឹងដែលមានទំហំសរុបរាប់រយហិចតានឹងត្រូវស្ថិតថេរនិងព័ទ្ធជុំវិញដោយមហាវិថី និងកន្លែងដើរកំសាន្តសាធារណៈនៅជុំវិញបឹង។ បឹងនេះនឹងរៀបចំឲ្យមានច្រាំងទប់កុំឲ្យលិចទឹក និងសួនច្បារសាធារណៈនៅលើត្រើយទាំងសងខាង។ រូបភាពនេះឆ្លុះបង្ហាញឲ្យឃើញទេសភាពក្រុងមួយបែបដែលលម្អដោយទឹក។
ភាពប្លែកពីគេរបស់វានោះ គឺការបង្កើត រោបនដ្ឋាន ( កន្លែងដាំដុះ ) នៅលើបឹងដើម្បីបន្សុទ្ធទឹក។ មួយវិញទៀតគេក៏អាចបន្តថែរក្សាទម្រង់កសិកម្មលើក្បួន ដែលបង្កើតបានជាទេសភាពល្អឯក «បឹងបៃតង» នៃប្រទេសកម្ពុជា។
ការបង្កើតទេសភាពថ្មីមួយចេញពីការប្រើប្រាស់ទឹកទៅតាមគ្រប់ទម្រង់នគរូបនីយកម្មតំបន់ភាគខាងត្បូងទទួលប្រយោជន៍ពីវត្តមាននៃទឹក។
បឹងជើងឯកនឹងក្លាយបឹងកណ្តាលក្រុងមួយ តែប្រឡាយក៏នឹងក្លាយជាទេសភាពល្អប្លែកៗមួយបែបផងដែរ។ ច្រាំងប្រឡាយទាំងអស់នឹងត្រូវអមទៅដោយផ្លូវសាធារណៈ ដែលមានដាំដើមឈើ។ ច្រាំងប្រឡាយនឹងមានដាំដើមឈើដែលសម្របខ្លួនទៅតាមទឹកជំនន់។
ដូច្នេះ ទេសភាពថ្មីមួយនឹងកើតមានឡើងដែលទេសភាពនៅទីនោះនឹងខុសប្លែកគ្នា ទៅតាមរដូវ និង តាមកម្រិតកំពស់ទឹកបឹង និងប្រឡាយ។
ការធ្វើបែបនេះនឹងអាចជួយការពារប្រព័ន្ធជារាសាស្ត្រទាំងមូលប្រកបដោយចីរភាព និងសម្រាប់លើកតម្លៃដល់សង្កាត់ថ្មីៗ។

**ដូឡូរ៉េស ប៊ែកត្រេ** Dolorés Bertrais
**ជាម ផាន្និន** Cheam Phanin